# ចាក់សោ ចោល !






ដោយ អែមបើរ ហ៊ុលី
( ផ្អែកទៅលើដំណើររឿងពិត )

*« ចូរដាក់ទីទុកចិត្តរបស់អ្នកទៅនឹងព្រះវិញ្ញាណនោះដែលនាំឲ្យធ្វើល្អ » ( គោលលទ្ធិ និង សេចក្ដីសញ្ញា ១១:១២ ) ។*

អិមម៉ា បានលោតនៅលើថ្មប្រះៗនៅលើចិញ្ចើមផ្លូវ ។ វាជាថ្ងៃមួយដែលព្រះអាទិត្យបើកថ្ងៃថែស ។ នាង និងម៉ាក់ កំពុងដើរទៅហាងលក់គ្រឿងទេស ។

នាងបានសួរថា « ម៉ាក់ តើព្រះអាទិត្យមានចម្ងាយប៉ុណ្ណា ? »

ម៉ាក់ បានឆ្លើយថា « ម៉ាក់មិនប្រាកដទេ » ។

អិមម៉ា បានបើកភ្នែកព្រឹមៗមើលទៅលើមេឃ ។ « តើម៉ាក់គិតថារ៉ុកកែតអាចទៅដល់ព្រះអាទិត្យឬទេ ? តើម៉ាក់គិតថាវាក្ដៅជាងរន្ធះដែរឬទេ ? តើម៉ាក់គិតថា . . . »

ម៉ាក់បានអស់សំណើច ។ « សំណួររបស់កូនកាន់តែពិបាកឡើងៗ ! »

អិមម៉ា ក៏អស់សំណើចដែរ ។ នាងមានសំណួរច្រើនណាស់ ។ ម៉ាក់តែងតែខិតខំអស់ពីសមត្ថភាពដើម្បីឆ្លើយសំណួរទាំងនោះ ។ នោះជាមូលហេតុមួយដែលអិមម៉ា ចូលចិត្តដើរជាមួយម៉ាក់ ។



*ប្រហែលជា អិមម៉ា អាចជួយបាន !*

អិមម៉ា បានមើលជុំវិញតំបន់ជិតខាងនាង ។ ឡានតាក់ស៊ីបានបើកចុះតាមផ្លូវថ្ម ។ មនុស្សម្នាបាននាំគ្នាជិះកង់ ។ មនុស្សម្នាជាច្រើនក៏បានចេញក្រៅដើរផងដែរ ។

បន្ទាប់មកអិមម៉ា បានមើលទៅផ្លូវម្ខាងទៀត ។ មានក្មេងស្រីម្នាក់កំពុងអង្គុយលើកាំជណ្ដើរខាងក្រៅអគារជួលមួយ ។ នាងហាក់ដូចជាកំពុងយំ ។

អិមម៉ា បន្ថយល្បឿនដើរ ។ តើនាងគួរតែឈប់ដើម្បីជួយដែរឬទេ ? ប្រហែលជាក្មេងស្រីម្នាក់នេះចង់នៅតែម្នាក់ឯងទេដឹង ។ នៅពេលខ្លះ អិមម៉ា ក៏ចង់នៅតែម្នាក់ឯងដែរ នៅពេលនាងមិនសប្បាយចិត្ត ។

អិមម៉ា បានឈប់ដើរ ។ ភាគច្រើន អិមម៉ា ចង់ឲ្យមាននរណាម្នាក់ដែលនាងអាចនិយាយជាមួយ នៅពេលនាងត្រូវការជំនួយ ។ ហើយប្រហែលជា*នាង*អាចជួយបាន !

នាងបានចាប់ដៃម៉ាក់ ។ « ម៉ាក់ មើលហ្នំ ។ កូនគិតថា ក្មេងស្រីនោះត្រូវការជំនួយហើយ » ។

ម៉ាក់បានមើលទៅផ្លូវម្ខាងទៀត ។ « ម៉ាក់គិតថា កូននិយាយត្រូវហើយ » ។

អិមម៉ា បានកាន់ដៃម៉ាក់ នៅពេលពួកគេបានដើរឆ្លងផ្លូវ ។ នាងបានឡើងកាំជណ្ដើរដល់កន្លែងដែលក្មេងស្រីនោះកំពុងអង្គុយ ។ អិមម៉ា បាននិយាយថា « សួស្ដី » ។ « តើឯងត្រូវការជំនួយទេ ? »

ក្មេងស្រីរូបនោះបានស្រូបដង្ហើម ចូលហើយបានមើលទៅពួកគេ ។ ដៃរបស់នាងបានឱបក្បាល ជង្គង់ទាំងពីរ ហើយភ្នែករបស់នាងឡើងពណ៌ក្រហម និងហើម ។

« ខ្ញុំ . . . ខ្ញុំត្រូវបានគេចាក់សោចោលក្រៅផ្ទះ » ។ នាងបានដកដង្ហើមធំ ។ សំលេងរបស់នាងឡើងញ័រ និងតិចៗ ។ អិមម៉ា បានលុតជង្គង់ចុះនៅ ក្បែរនាង ដើម្បីស្ដាប់នាងនិយាយឲ្យបានច្បាស់ ។

ក្មេងស្រីនោះបាននិយាយថា « ខ្ញុំមិនចេះអានអក្សរទេ » ។ « ខ្ញុំមិនដឹងថា ប៊ូតុងណាមួយដែលត្រូវចុចដើម្បី ចូលផ្ទះវិញបានទេ » ។

អិមម៉ា បានមើលទៅជញ្ជាំង នៅខាងក្រៅអគារជួល ។ មានប៊ូតុងតូចៗជាច្រើន ។ នៅលើប៊ូតុងនីមួយៗមានឈ្មោះវា ។ នៅជិតប៊ូតុងនោះគឺ មានមេក្រូមួយ ។

អិមម៉ា បានសួរ  « តើនាមត្រកូលឯងឈ្មោះអី ? » ។

ក្មេងស្រីតូចនោះបាននិយាយថា « ស្នែជឺរ » ។

ម៉ាក់ បានអានប៊ូតុងទាំងអស់ រហូតដល់នាងបានឃើញប៊ូតុងមួយសរសេរថា « ស្នែជឺរ » ។ នាងបានចុចប៊ូតុងនោះ ។

*ក្រឹងៗ!*

ប៊ូតុងនោះមានសំឡេងលឺខ្លាំងណាស់ ។ បន្ទាប់មក មានសំឡេងមួយបានបន្លឺឡើងចេញពីមេក្រូនោះ ។

« នេះជាគ្រួសារស្នែជឺរ ។ មានអ្វីខ្ញុំអាចជួយអ្នកបាន ? »

ម៉ាក់ បាននិយាយឆ្លើយមេក្រូវិញ ។ « ជម្រាបសួរ ! កូនស្រីខ្ញុំ និងខ្ញុំនៅខាងក្រៅជាមួយក្មេងស្រីម្នាក់ដែលនិយាយថា នាងត្រូវបានគេចាក់សោចោល » ។

ក្មេងស្រីនោះបានងើបយ៉ាងលឿន ហើយរត់ទៅឆ្លើយតបតាមមេក្រូវិញ ។ នាងនិយាយថា « ម៉ាក់ កូនអត់ចេះអានអក្សរលើប៊ូតុងដើម្បីចុចចូលក្នុងផ្ទះវិញទេ ហើយពួកគាត់បានជួយកូន ! » ។

សំឡេងឆ្លើយតាមមេក្រូបានភ្ញាក់ផ្អើល ។ « លេនី! ម៉ាក់ស្មានតែកូននៅក្នុងបន្ទប់កូន ! កុំខ្លាចអី ។ ម៉ាក់ចុះក្រោមឥឡូវនេះ » ។

ពីរបីនាទីក្រោយមក មានស្ត្រី ម្នាក់រត់ចេញមកក្រៅ ។ ក្មេងស្រីនោះបានរត់ទៅជួប ហើយឱបគាត់ ។

ស្ត្រីរូបនោះបានងាកទៅអិមម៉ា ។ « អរគុណដែលបានជួយកូនស្រី លេនីដ៏តូចរបស់ខ្ញុំ ! »

អិមម៉ា បានញញឹម ។ « ការជួយវាងាយស្រួលណាស់ » ។



ពួកគេបានលើកដៃគ្រវីលាគ្នា ហើយបានដើរចុះពីជណ្ដើរវិញ ។ រូបកាយទាំងមូលរបស់អិមម៉ាមានអារម្មណ៍កក់ក្ដៅ ។ នាងបានចង់សួរម៉ាក់មួយសំណួរទៀត ។

« ការជួយដល់ក្មេងស្រីនោះគឺ តិចតួច ងាយស្រួលណាស់ ។ ហេតុអ្វី កូនមានអារម្មណ៍សប្បាយចិត្តអំពីរឿងនេះ ? »

ម៉ាក់បានច្របាច់ដៃអិមម៉ា ។ « នោះគឺជាព្រះវិញ្ញាណបរិសុទ្ធកំពុងមានបន្ទូលប្រាប់កូនថា កូនបានធ្វើការជ្រើសរើសត្រឹមត្រូវមួយ » ។

អិមម៉ា បានញញឹម ។ នាងសប្បាយចិត្តដែលបានឈប់ដើម្បី ជួយ ។●

*ដំណើររឿងនេះបានកើតឡើងនៅហុងគ្រី ហុងគ្រី កណ្ដាល ។ អ្នកនិពន្ធរស់នៅរដ្ឋយូថាហ៍ ស.រ.អ. ។.*